# សេចក្តីសង្ខេបអត្ថប្រយោជន៍ *ឆ្នាំ 2018*

*Health Net Cal MediConnect Plan (Medicare-Medicaid Plan)*

**Los Angeles County, CA**

H3237_18_001_SBR_CMB_Accepted_05112018

Health Net®

# Health Net Cal MediConnect
# សេចក្តីសង្ខេបអត្ថប្រយោជន៍

**!** នេះគឺជាសេចក្តីសង្ខេបនៃសេវាសុខភាព ដែលរ៉ាប់រងដោយ Health Net Cal MediConnect Plan (Medicare-Medicaid Plan) សំរាប់ថ្ងៃទី 1 ខែមករា 2018។ នេះគឺគ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ។ សូមអាន*សៀវភៅណែនាំសមាជិក* សំរាប់បញ្ជីពេញលេញនៃអត្ថប្រយោជន៍។

- Health Net Community Solutions, Inc. គឺជាគំរោងសុខភាពមួយ ដែលមានកិច្ចសន្យាជាមួយទាំង Medicare និង Medi-Cal ដើម្បីផ្តល់អត្ថប្រយោជន៍នៃកម្មវិធីទាំងពីរមុខ សំរាប់អ្នកចុះឈ្មោះ។ វាគឺសំរាប់មនុស្សដែលមាន Medicare និង Medi-Cal។
- នៅក្រោម Health Net Cal MediConnect អ្នកអាចទទួលសេវា Medicare និង Medi-Cal របស់អ្នក ក្នុងគំរោងសុខភាពតែមួយ។ អ្នកសំរបសំរួលការថែទាំ Health Net Cal MediConnect នឹងជួយចាត់ចែងសេចក្តីត្រូវការ នៃការថែទាំសុខភាពរបស់អ្នក។
- នេះមិនមែនជាបញ្ជីសព្វគ្រប់ទេ។ ព័ត៌មានអត្ថប្រយោជន៍ គឺជាសេចក្តីសង្ខេបត្រួសៗ ហើយមិនមែនជាការរៀបរាប់សព្វគ្រប់នៃអត្ថប្រយោជន៍ឡើយ។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងគំរោងសុខភាព ឬអាន*សៀវភៅណែនាំសមាជិក*។
- ការកំរិត ថ្លៃរួមបង់ និងលក្ខខ័ណ្ឌ អាចនឹងពាក់ព័ន្ធ។ សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅផ្នែកសេវាសមាជិក Health Net Cal MediConnect ឬអាន*សៀវភៅណែនាំសមាជិក* Health Net Cal MediConnect។
- *បញ្ជីឱសថដែលរ៉ាប់រង* និង/ឬ បណ្តាញឱសថស្ថាន និងអ្នកផ្តល់សេវា អាចនឹងផ្លាស់ប្តូរនៅទូទាំងឆ្នាំ។ យើងនឹងផ្ញើលិខិតជូនដំណឹងទៅអ្នក មុននឹងយើងផ្លាស់ប្តូរ ដែលប៉ះពាល់ដល់អ្នក។
- អត្ថប្រយោជន៍ និង/ឬ ថ្លៃរួមបង់ អាចនឹងផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា រៀងរាល់ឆ្នាំ។
- ថ្លៃរួមបង់ សំរាប់ឱសថមានវេជ្ជបញ្ជាអាចនឹងខុសៗគ្នា យោងលើកំរិតជំនួយបន្ថែមដែលអ្នកទទួល។ សូមទាក់ទងគំរោង សំរាប់សេចក្តីពិស្តារថែមទៀត។
- អ្នកអាចទទួលបានព័ត៌មាននេះដោយឥតគិតថ្លៃ ជាទំរង់ផ្សេងទៀត ដូចជា អក្សរពុម្ពធំៗ អក្សរប្រ៊ែល ឬថាសសំឡេង។ ទូរស័ព្ទទៅលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ ការហៅនេះ គឺឥតចេញថ្លៃឡើយ។
- បើសិនអ្នកចង់ឲ្យ Health Net Cal MediConnect ផ្ញើទៅឲ្យអ្នក នូវសំភារៈសំរាប់សមាជិក ជាហូរហែទៀតទាត់ ជាទំរង់ផ្សេងទៀត ដូចជា អក្សរប្រ៊ែល ឬអក្សរពុម្ពធំៗ ឬជាភាសាផ្សេងទៀតក្រៅពីអង់គ្លេស សូមទាក់ទងផ្នែកសេវាសមាជិក។ ប្រាប់ផ្នែកសេវាសមាជិក ថាអ្នកចង់បានសំភារៈរបស់អ្នកជាទំរង់ ឬភាសាមួយទៀត ជាអចិន្ត្រៃយ៍។

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

# Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

If you do not speak English, language assistance services, free of charge, are available to you. Call 1-855-464-3571 (TTY: 711) from 8 a.m. to 8 p.m., Monday through Friday. After hours, on weekends and on holidays, you can leave a message. Your call will be returned within the next business day. The call is free.

إذا كنت تتحدث العربية، تتوافر لك خدمات المساعدة اللغوية مجانًا. يُرجى الاتصال بالرقم 1-855-464-3571 (TTY: 711)، من الساعة 8:00 صباحًا حتى 8:00 مساءً، من يوم الاثنين إلى الجمعة، وللاتصال في غير أوقات الدوام الرسمي، أيام الأجازات والعطلات ، يمكنك ترك رسالة. سنرد على مكالمتك في يوم العمل التالي. هذه المكالمة مجانية.

Եթե Հայերեն եք խոսում, անվճար լեզվական օգնության ծառայություններ են հասնում Ձեզ : Զանգահարեք 1-855-464-3571 (TTY՝ 711): Մի անձ այստեղ է Ձեզ հետ զրուցելու նպատակով երկուշաբթիից ուրբաթ, կ.ա. 8:00-ից կ.հ. 8:00-ը: Աշխատանքային ժամերից անց, հանգստյան օրերին եւ տոներին, կարող եք թողնել հաղորդագրություն: Ձեր զանգը կվերադարձվի հաջորդ աշխատանքային օրվա ընթացքում: Հեռախոսազանգն անվճար է:

如果您使用中文，您可以免費獲得語言援助服務。請致電 1-855-464-3571 (聽障專線：711)。週一至週五，上午8點到下午8點。非營業時間、週末及假日，您可以留言。我們會在下一個工作日給您回電。此專線爲免付費電話。

បើសិនអ្នកនិយាយភាសាខ្មែរ សេវាជំនួយភាសាឥតគិតថ្លៃ គឺមានសំរាប់អ្នក។ ទូរស័ព្ទទៅលេខ 1-855-464-3571 (TTY:711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ ការហៅនេះ គឺឥតចេញថ្លៃឡើយ។

اگر به فارسی صحبت می کنید، خدمات امداد زبانی به طور رایگان در اختیار شما می باشند. با شماره 1-855-464-3571(TTY: 711) از ساعت 8:00 صبح تا 8:00 شب، دوشنبه تا جمعه تماس بگیرید. بعد از ساعات کاری، در آخر هفته ها و تعطیلات رسمی، می توانید پیام بگذارید. به تماس تلفنی شما در روز کاری بعدی پاسخ داده خواهد شد. این تماس رایگان است.

귀하께서한국어를 사용하시는 경우 언어 지원 서비스를 무료로 이용하실 수 있습니다. 1-855-464-3571(TTY: 711)번으로 월요일 - 금요일, 오전 8시부터 오후 8시까지 전화하십시오. 영업시간 이후, 주말 및 공휴일에는 메시지를 남기실 수 있습니다. 다음 영업일에 저희가 귀하께 전화를 드리겠습니다. 안내전화는 무료입니다.

? **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

Если вы говорите по-русски, мы можем предложить вам бесплатные услуги переводчика. Звоните по телефону 1-855-464-3571 (линия TTY: 711). Вы можете получить необходимую информацию непосредственно у сотрудника плана с понедельника по пятницу с 8:00 часов утра до 8:00 часов вечера. В нерабочее время, а также в выходные и праздничные дни, вы можете оставить сообщение. Вам перезвонят на следующий рабочий день. Звонок бесплатный.

Si usted habla español, hay servicios de asistencia de idiomas disponibles para usted sin cargo. Llame al 1-855-464-3571 (TTY: 711). Después del horario de atención, los fines de semana y los días feriados puede dejar un mensaje. Le devolveremos la llamada el siguiente día hábil. La llamada es gratuita.

Kung nagsasalita ka ng Tagalog, available sa inyo ang mga serbisyo ng tulong sa wika, nang walang singil. Tumawag sa 1-855-464-3571 (TTY: 711) mula 8 a.m. hanggang 8 p.m., Lunes hanggang Biyernes. Paglipas ng mga oras ng negosyo, tuwing Sabado at Linggo at sa pista opisyal, maaari kang mag-iwan ng mensahe. Ang iyong tawag ay ibabalik sa loob ng susunod na araw ng negosyo. Libre ang tawag.

Nếu quý vị nói tiếng Việt, chúng tôi sẵn có dịch vụ hỗ trợ ngôn ngữ miễn phí dành cho quý vị. Hãy gọi 1-855-464-3571 (TTY: 711) từ 8 giờ sáng đến 8 giờ tối, từ thứ Hai đến hết thứ Sáu. Sau giờ làm việc, vào các ngày cuối tuần và ngày lễ, quý vị có thể để lại tin nhắn. Cuộc gọi của quý vị sẽ được hồi đáp vào ngày làm việc hôm sau. Cuộc gọi này miễn phí.

# Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

**តារាងនៅខាងក្រោម គឺជាបញ្ជី សំណួរដែលចោទសួរញឹកញាប់ (Frequently Asked Question, FAQ)។**

| សំណួរដែលចោទសួរញឹកញាប់ (FAQ) | ចំឡើយ |
|---|---|
| **តើគំរោង Cal MediConnect ជាអ្វី?** | គំរោង Cal MediConnect Plan ជាអង្គការមួយដែលមាននូវវេជ្ជបណ្ឌិត មន្ទីរពេទ្យ ឱសថស្ថាន អ្នកផ្តល់សេវាយូរអង្វែង និងអ្នកផ្តល់សេវាផ្សេងទៀត។ វាក៏មាន អ្នកសំរបសំរួលការថែទាំសុខភាព (Health Care Coordinator) ដើម្បីជួយអ្នកចាត់ចែងអ្នកផ្តល់សេវា និងសេវារបស់អ្នកទាំងអស់។ គេធ្វើការរួមគ្នា ដើម្បីផ្តល់ការថែទាំដែលអ្នកត្រូវការ។ Health Net Cal MediConnect Plan (Medicare-Medicaid Plan) គឺជា Cal MediConnect Plan ដែលផ្តល់អត្ថប្រយោជន៍នៃ Medi-Cal និង Medicare សំរាប់អ្នកចុះឈ្មោះ។ |
| **តើអ្នកសំរបសំរួលការថែទាំ Health Net Cal MediConnect ជាអ្វី?** | អ្នកសំរបសំរួលការថែទាំ Health Net Cal MediConnect គឺជាមនុស្សចំបង សំរាប់អ្នកទាក់ទងមក។ មនុស្សនេះជួយចាត់ចែងអ្នកផ្តល់សេវា និងសេវាទាំងអស់របស់អ្នក និងធ្វើឲ្យប្រាកដ ថាអ្នកទទួលបានអ្វីៗដែលអ្នកត្រូវការ។ |
| **តើ គ្រប់គ្រងសេវា និងការគាំទ្រយូរអង្វែង (Long-Term Services and Supports, LTSS) ជាអ្វី?** | គ្រប់គ្រងសេវា និងការគាំទ្រយូរអង្វែង (Long-Term Services and Supports, LTSS) គឺសំរាប់អ្នកទទួលអត្ថប្រយោជន៍ ដែលត្រូវការជំនួយដើម្បីធ្វើកិច្ចការប្រចាំថ្ងៃ ដូចជាការងូតទឹក ការស្លៀកពាក់ ការដាំស្ល និងការលេបថ្នាំ ជាដើម។ ភាគច្រើន នៃសេវាទាំងនេះ ត្រូវបានផ្តល់នៅផ្ទះរបស់អ្នក ឬក្នុងសហគមន៍របស់អ្នក ប៉ុន្តែអាចនឹងបានផ្តល់នៅក្នុងលំនៅពេទ្យ ឬមន្ទីរពេទ្យ។<br><br>LTSS រួមមានកម្មវិធីដូចតទៅ៖ កម្មវិធីសេវាព្រឹទ្ធាវ័យ ពហុគោលបំណង (Multipurpose Senior Services Program, MSSP), សេវាមនុស្សពេញវ័យតាមសហគមន៍ (Community-Based Adult Services, CBAS), និងការថែទាំយូរអង្វែងនៅក្នុងមន្ទីរថែទាំជំងឺមានជំនាញ បានផ្តល់ដោយ មន្ទីរថែទាំជំងឺ (Nursing Facilities, NF)។ |
| **តើអ្នកនឹងទទួលអត្ថប្រយោជន៍ Medicare និង Medi-Cal ដូចគ្នានៅក្នុង Health Net Cal MediConnect ដែលអ្នកទទួលនៅពេលឥឡូវនេះ ឬទេ?** | អ្នកនឹងទទួលអត្ថប្រយោជន៍នៃ Medicare និង Medi-Cal ដែលរ៉ាប់រង ស្ទើរតែទាំងអស់ ចេញពី Health Net Cal MediConnect ដោយផ្ទាល់។ អ្នកនឹងធ្វើការជាមួយនឹងអ្នកផ្តល់សេវាមួយក្រុម ដែលនឹងជួយសំរេចអំពីសេវាអ្វីខ្លះ នឹងស្របតាមសេចក្តីត្រូវការរបស់អ្នក បានល្អបំផុត ។ នេះមានន័យថាសេវាមួយចំនួនដែលអ្នកទទួលនៅឥឡូវនេះ អាចនឹងផ្លាស់ប្តូរ។ នៅពេលអ្នកចុះឈ្មោះក្នុង Health Net Cal MediConnect រូបអ្នក និងក្រុមថែទាំរបស់អ្នក នឹងធ្វើការរួមគ្នា ដើម្បីបង្កើតគំរោងថែទាំតាមភាពបុគ្គលមួយ ដើម្បីដោះស្រាយបញ្ហាសុខភាពរបស់អ្នក និងសេចក្តីត្រូវការគាំទ្រ ដែលឆ្លុះបញ្ចាំងនូវចំណង់ និងគោលដៅផ្ទាល់ខ្លួនរបស់អ្នក។<br><br>មិនតែប៉ុណ្ណោះ បើអ្នកលេបឱសថមានវេជ្ជបញ្ជា Medicare Part D អ្វីមួយ ដែលតាមធម្មតា Health Net Cal MediConnect មិនរ៉ាប់រង អ្នកអាចទទួលការផ្គត់ផ្គង់ជាបណ្តោះអាសន្ន ហើយយើងនឹងជួយអ្នកធ្វើការផ្លាស់ប្តូរ ទៅឱសថមួយទៀត ឬទទួលការអនុគ្រោះពី Health Net Cal MediConnect ដើម្បីរ៉ាប់រងឱសថរបស់អ្នក បើសិនជាធាតាព្យាបាលចាំបាច់។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

# Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

| សំណួរដែលចោទសួរញឹកញាប់ (FAQ) | ចំឡើយ |
| --- | --- |
| **តើអ្នកអាចទៅជួបវេជ្ជបណ្ឌិតដដែល ដែលអ្នកជួបឥឡូវនេះ បានឬទេ?** | ជាញឹកញាប់ គឺអាចជួបបាន។ បើសិនអ្នកផ្តល់សេវារបស់អ្នក (រួមទាំងវេជ្ជបណ្ឌិត និងឱសថស្ថាន) ធ្វើការជាមួយ Health Net Cal MediConnect និងមានកិច្ចសន្យាជាមួយយើង អ្នកអាចរក្សាការទៅជួបគេទៀត។ អ្នកផ្តល់សេវាដែលមានកិច្ចព្រមព្រៀងជាមួយយើង គឺធ្វើការ "ក្នុងបណ្តាញ"។ អ្នកត្រូវតែប្រើអ្នកផ្តល់សេវានៅក្នុងបណ្តាញរបស់ Health Net Cal MediConnect។ បើសិនអ្នកត្រូវការសេវាថែទាំសុខភាពជាបន្ទាន់ ឬសេវាលាងតម្រងនោមនៅក្រៅតំបន់ អ្នកអាចប្រើអ្នកផ្តល់សេវាក្រៅគំរោងរបស់ Health Net Cal MediConnect បាន។ សំរាប់ព័ត៌មានបន្ថែម អំពីការជួបអ្នកផ្តល់សេវានៅក្រៅបណ្តាញរបស់ Health Net Cal MediConnect សូមទូរស័ព្ទទៅផ្នែកសេវាសមាជិក ឬអាន*សៀវភៅណែនាំសមាជិក* របស់ Health Net Cal MediConnect។<br><br>ដើម្បីសាកសួរ បើសិនវេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងបណ្តាញរបស់គំរោងឬអត់ ទូរស័ព្ទទៅផ្នែកសេវាសមាជិក ឬអាន*បញ្ជីឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថាន* របស់ Health Net Cal MediConnect។<br><br>បើសិន Health Net Cal MediConnect ជាគំរោងថ្មីសំរាប់អ្នក យើងនឹងធ្វើការជាមួយអ្នក ដើម្បីបង្កើតគំរោងថែទាំតាមភាពបុគ្គលមួយ ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់អ្នក។ អ្នកអាចបន្តទៅជួបវេជ្ជបណ្ឌិត ដែលអ្នកទៅជួបឥឡូវនេះ ដល់ទៅចំនួន 12 ខែ បើសិនគេផ្តល់សេវា ដែល Medicare និង Medi-Cal នឹងរ៉ាប់រង និងបានស្របតាមលក្ខខ័ណ្ឌខ្លះ។ សូមទូរស័ព្ទទៅផ្នែកសេវាសមាជិក តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ និងប្រាប់គេថាអ្នកចង់ស្នើសុំនិរន្តរភាពថែទាំ។ |
| **តើមានអ្វីកើតឡើង បើអ្នកត្រូវការសេវា ប៉ុន្តែពុំមានបណ្តាញមួយរបស់ Health Net Cal MediConnect អាចផ្តល់វា?** | សេវាភាគច្រើន នឹងបានផ្តល់ដោយអ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើង។ បើសិនអ្នកត្រូវការសេវា ដែលមិនអាចផ្តល់នៅក្នុងបណ្តាញរបស់យើងបាន Health Net Cal MediConnect នឹងបង់តម្លៃ សំរាប់អ្នកផ្តល់សេវានៅក្រៅបណ្តាញ។ |
| **តើ Health Net Cal MediConnect មាននៅទីណា?** | តំបន់សេវាសំរាប់គំរោងនេះ រួមមាននូវៈ Los Angeles County, CA (ដោយមានការលើកលែងតែស៊ីបកូដៈ 90704)។ អ្នកត្រូវតែរស់នៅក្នុងតំបន់នេះ ដើម្បីចូលរួមក្នុងគំរោងបាន។ |
| **តើអ្នកបង់ចំនួនប្រចាំខែ (ក៏ហៅថា ថ្លៃបង់ធានារ៉ាប់រង) នៅក្រោម Health Net Cal MediConnect ឬទេ?** | អ្នកនឹងមិនបង់ថ្លៃធានារ៉ាប់រងប្រចាំខែណាមួយ ទៅ Health Net Cal MediConnect សំរាប់ការរ៉ាប់រងសុខភាពរបស់អ្នកទេ។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

| សំណួរដែលចោទសួរញឹកញាប់ (FAQ) | ចំឡើយ |
|---|---|
| **តើការអនុញ្ញាតជាមុន ជាអ្វី?** | ការអនុញ្ញាតជាមុន មានន័យថាអ្នកត្រូវតែបានទទួលការយល់ព្រមពី Health Net Cal MediConnect មុននឹងអ្នកអាចទទួលសេវា ឬឱសថខ្លះ ឬទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ។ Health Net Cal MediConnect អាចនឹងមិនរ៉ាប់រងសេវា ឬឱសថទេ បើអ្នកមិនបានទទួលការយល់ព្រម។<br><br>បើសិនអ្នកត្រូវការសេវាថែទាំជាបន្ទាន់ ឬក្នុងគ្រាអាសន្ន ឬសេវាលាងតម្រងនោមនៅក្រៅតំបន់ អ្នកមិនចាំបាច់ទទួលការយល់ព្រមជាមុនសិនទេ។ Health Net Cal MediConnect អាចផ្តល់ជូនអ្នក នូវបញ្ជីសេវា ឬទំរង់ការ ដែលតម្រូវឲ្យអ្នកទទួលការអនុញ្ញាតជាមុន ពី Health Net Cal MediConnect មុននឹងសេវាត្រូវបានផ្តល់ឲ្យ។ |
| **តើការបញ្ជូន ជាអ្វី?** | ការបញ្ជូន មានន័យថាអ្នកផ្តល់ការថែទាំជាបឋមរបស់អ្នក ត្រូវតែផ្តល់ការយល់ព្រមឲ្យអ្នក ដើម្បីទៅជួបអ្នកណាម្នាក់ ដែលមិនមែនជាអ្នកផ្តល់ការថែទាំជាបឋមរបស់អ្នក។ បើសិនអ្នកមិនបានការយល់ព្រមទេ Health Net Cal MediConnect អាចនឹងមិនរ៉ាប់រងសេវាឡើយ។ មានអ្នកឯកទេសខ្លះ ដែលអ្នកមិនបាច់ត្រូវការនូវការបញ្ជូន ដូចជាអ្នកឯកទេសខាងសុខភាពរបស់ស្ត្រី។ សំរាប់ព័ត៌មានបន្ថែម អំពីពេលណាការបញ្ជូនជាចាំបាច់ សូមមើល *សៀវភៅណែនាំសមាជិក*។ |
| **តើជំនួយបន្ថែម ជាអ្វី?** | ជំនួយបន្ថែម គឺជាកម្មវិធី Medicare ដែលជួយកាត់បន្ថយការបង់ថ្លៃកម្មវិធីឱសថមានវេជ្ជបញ្ជារបស់អ្នក ដូចជាថ្លៃរួមបង់។ ថ្លៃរួមបង់ ឱសថមានវេជ្ជបញ្ជារបស់អ្នក នៅក្រោម Health Net Cal MediConnect បានបញ្ចូលរួចហើយ នូវចំនួនជំនួយបន្ថែម ដែលអ្នកមានសិទ្ធិទទួល។ សំរាប់ព័ត៌មានបន្ថែមអំពីជំនួយបន្ថែម សូមទាក់ទងការិយាល័យសូស្យាល់សឺគ្យូរិទី តាមមូលដ្ឋានរបស់អ្នក ឬទូរស័ព្ទទៅសូស្យាស់សឺគ្យូរិទី តាមលេខ 1-800-772-1213។ អ្នកប្រើ TTY គួរតែហៅលេខ 1-800-325-0778។ |

| សំណួរដែលចោទសួរញឹកញាប់ (FAQ) | ចំឡើយ |
|---|---|
| **តើអ្នកគួរតែទាក់ទងអ្នកណា បើសិនអ្នកមានសំណួរ ឬត្រូវការជំនួយ?** | **បើសិនអ្នកមានសំណួរទូទៅ ឬសំណួរអំពីគំរោង សេវា តំបន់សេវារបស់យើង ឬអំពីវិក្កយប័ត្រ ឬប័ណ្ណ ID សមាជិក សូមទូរស័ព្ទទៅផ្នែកសេវាសមាជិក Health Net Cal MediConnect។**<br>**ហៅ:** 1-855-464-3571<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ មនុស្សមែនទែននៅទីនេះ អាចនិយាយជាមួយអ្នក ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។<br>ផ្នែកសេវាសមាជិក ក៏មានសេវាបកប្រែភាសា ដោយឥតគិតថ្លៃ សំរាប់អ្នកដែលមិនចេះនិយាយភាសាអង់គ្លេសដែរ។<br>**TTY:** 711<br>លេខនេះគឺសំរាប់មនុស្សដែលមានបញ្ហានឹងការស្តាប់ ឬនិយាយស្តី។ អ្នកត្រូវតែមានគ្រឿងទូរស័ព្ទពិសេស ទើបហៅវាបាន។<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ មនុស្សមែនទែននៅទីនេះ អាចនិយាយជាមួយអ្នក ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។<br>**បើសិនអ្នកមានសំណួរអំពីសុខភាពរបស់អ្នក សូមទូរស័ព្ទទៅ ខ្សែឱវាទពេទ្យចាំទូរស័ព្ទ (Nurse Advice Call Line)។**<br>**ហៅ:** 1-855-464-3571<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ ការបង្ហាត់ និងឱវាទពេទ្យ មកពីអ្នកព្យាបាលដែលបានហ្វឹកហ្វឺន គឺមាន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយអាទិត្យ។<br>**TTY:** 711<br>លេខនេះគឺសំរាប់មនុស្សដែលមានបញ្ហានឹងការស្តាប់ ឬនិយាយស្តី។ អ្នកត្រូវតែមានគ្រឿងទូរស័ព្ទពិសេស ទើបហៅវាបាន។<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ ការបង្ហាត់ និងឱវាទពេទ្យ មកពីអ្នកព្យាបាលដែលបានហ្វឹកហ្វឺន គឺមាន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយអាទិត្យ។ |

? **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

| សំណួរដែលចោទសួរញឹកញាប់ (FAQ) | ចំឡើយ |
|---|---|
| **តើអ្នកគួរតែទាក់ទងអ្នកណា បើសិនអ្នកមានសំណួរ ឬត្រូវការជំនួយ?**<br>*(បន្ត)* | **បើសិនអ្នកត្រូវការសេវាសុខភាពឥរិយាបថ សូមទូរស័ព្ទទៅ ខ្សែវិបត្តិសុខភាពឥរិយាបថ (Behavioral Health Crisis Line)។**<br>**ហៅ:** 1-855-464-3571<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ អ្នកព្យាបាលសុខភាពឥរិយាបថមានអាជ្ញាប័ណ្ណ គឺមាន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃ មួយអាទិត្យ។<br>**TTY:** 711<br>លេខនេះគឺសំរាប់មនុស្សដែលមានបញ្ហានឹងការស្តាប់ ឬនិយាយស្តី។ អ្នកត្រូវតែមានគ្រឿងទូរស័ព្ទពិសេស ទើបហៅវាបាន។<br>ហៅមកលេខនេះ គឺឥតចេញថ្លៃឡើយ។ អ្នកព្យាបាលសុខភាពឥរិយាបថមានអាជ្ញាប័ណ្ណ គឺមាន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃ មួយអាទិត្យ។ |

# Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

**តារាងនៅខាងក្រោម គឺជាទិដ្ឋភាពសង្ខេបគ្រួសៗ នៃសេវាអ្វីខ្លះដែលអ្នកអាចនឹងត្រូវការ ព្រមទាំងតម្លៃ និងវិន័យអំពីអត្ថប្រយោជន៍ របស់អ្នក។**

| សេចក្តីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្តល់សេវាក្នុងបណ្តាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកចង់ទៅជួបវេជ្ជបណ្ឌិត** | ជួបពិគ្រោះ ដើម្បីព្យាបាលរបួស ឬជំងឺ | $0 | បើសិនអ្នកត្រូវការសេវាថែទាំជាបន្ទាន់ ឬក្នុងគ្រាអាសន្ន ឬសេវាលាងតម្រងនោម នៅក្រៅតំបន់ អ្នកមិនចាំបាច់ទទួលការយល់ព្រមជាមុនសិនទេ។ សំរាប់ការជួបពិគ្រោះ ការបញ្ជូនប្រក្រតី និងវិន័យការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។<br>អ្នកត្រូវតែទៅជួបវេជ្ជបណ្ឌិត អ្នកឯកទេស និងមន្ទីរពេទ្យ នៅក្នុងបណ្តាញ។ |
| | ជួបពិគ្រោះជាសុកភាព ដូចជាពិនិត្យរូបកាយ | $0 | ជួបពិគ្រោះជាសុកភាពប្រចាំឆ្នាំ រៀងរាល់ 12 ខែ។ |
| | យានជំនិះ ទៅការិយាល័យវេជ្ជបណ្ឌិត | $0 | **មិនមែនយានជំនិះពេទ្យ (Non-Medical Transportation, NMT)** – គ្មានកំរិតដំណើរទៅមក ទៅកាន់ទីកន្លែងដែលគំរោងបានយល់ព្រម តាមឡានធម្មតា ឡានតាក់ស៊ី ឬទំរង់ ផ្សេងទៀត នៃយានជំនិះសាធារណៈ/ឯកជន រៀងរាល់ឆ្នាំ។ តម្រូវនូវការបញ្ជូន អាចនឹងអនុវត្ត។<br>**យានជំនិះពេទ្យមិនអាសន្ន (Non-Emergency Medical Transportation, NEMT)** – ជាចាំបាច់ដើម្បីទទួលសេវាដែលរ៉ាប់រង ហើយលក្ខណៈសុខភាពរបស់អ្នក មិនអនុញ្ញាតឲ្យអ្នកធ្វើដំណើរតាមឡានធម្មតា ឡានតាក់ស៊ី ឬទំរង់ផ្សេងទៀត នៃយានជំនិះសាធារណៈ/ឯកជន បាន។ វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | ការថែទាំពីអ្នកឯកទេស | $0 | អ្នកត្រូវតែទៅជួបវេជ្ជបណ្ឌិត អ្នកឯកទេស និងមន្ទីរពេទ្យ នៅក្នុងបណ្តាញ។ វិន័យការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ តម្រូវនូវការបញ្ជូន សំរាប់បណ្តាញអ្នកឯកទេស (សំរាប់អត្ថប្រយោជន៍ខ្លះ)។ |
| | ការថែទាំដើម្បីរក្សាអ្នកកុំឲ្យឈឺថ្កាត់ ដូចជាចាក់ថ្នាំការពារគ្រុនផ្តាសាយធំ | $0 | ការបញ្ជូន និងការអនុញ្ញាតជាមុន មិនត្រូវការទេ សំរាប់ការចាក់ថ្នាំបង្ការគ្រុនផ្តាសាយធំ ឬរោគហើមសួត។ វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត សំរាប់សេវាផ្សេងៗ។ |
| | ជួបពិគ្រោះបង្ការ "ស្វាគមន៍មក Medicare" (តែម្តងគត់) | $0 | ក្នុងអំឡុងពេល 12 ខែដំបូងនៃការរ៉ាប់រង Part B ថ្មីរបស់អ្នក អ្នកអាចជួបពិគ្រោះបង្ការ ស្វាគមន៍មក Medicare ឬជួបពិគ្រោះជាសុកភាពប្រចាំឆ្នាំ។ បន្ទាប់ពី 12 ខែដំបូងមក អ្នកអាចទទួលការជួបពិនិត្យជាសុកភាពប្រចាំឆ្នាំ រៀងរាល់ 12 ខែ។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

# Health Net Cal MediConnect: សេចក្ដីសង្ខេបអត្ថប្រយោជន៍

| សេចក្ដីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្ដល់សេវាក្នុងបណ្ដាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការធ្វើតេស្ដសុខភាព** | ធ្វើតេស្ដពិសោធន៍ ដូចជា ដោះឈាម | $0 | វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | អិក្សរេ ឬរូបភាពផ្សេងទៀត ដូចជាថត CAT | $0 | វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | ការធ្វើតេស្ដត្រួតពិនិត្យ ដូចជាធ្វើតេស្ដដែកមើលរោគមហារីក | $0 | អាស្រ័យទៅលើសេវា វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| **អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺ ឬលក្ខណៈជំងឺរបស់អ្នក** | ឱសថឈ្មោះធម្មតា (មិនមែនឈ្មោះល្បី) | ថ្លៃរួមបង់ $0 ដល់ $3.35 សំរាប់ការផ្គត់ផ្គង់ 30 ថ្ងៃ។<br><br>ថ្លៃរួមបង់ សំរាប់ឱសថមានវេជ្ជបញ្ជា អាចប្រែប្រួលអាស្រ័យលើកំរិត នៃជំនួយបន្ថែម ដែលអ្នកទទួល។ សូមទាក់ទងគំរោង សំរាប់សេចក្ដីពិស្ដារថែមទៀត។ | អាចនឹងមានកំរិត ទៅលើប្រភេទនៃឱសថដែលរ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលរ៉ាប់រង* (បញ្ជីឱសថ) របស់ Health Net Cal MediConnect សំរាប់ព័ត៌មានបន្ថែម។<br><br>អ្នកអាចនឹងទទួលឱសថរបស់អ្នក នៅឯបណ្ដាញឱសថស្ថានលក់រាយ និងឱសថស្ថានបញ្ជាទិញផ្ញើតាមប្រៃសណីយ៍ផ្សេងទៀត។<br><br>បើសិនអ្នករស់នៅ ក្នុងមន្ទីរថែទាំយូរអង្វែង អ្នកបង់ថ្លៃដូចនឹងឱសថស្ថានលក់រាយដែរ។<br><br>នៅក្នុងករណីតិចតួចប៉ុណ្ណោះ យើងខ្ញុំនឹងរ៉ាប់រងវេជ្ជបញ្ជាដែលបានបំពេញនៅឯឱសថស្ថានក្រៅបណ្ដាញ។ បើសិនអ្នកទៅឱសថស្ថានក្រៅបណ្ដាញ អ្នកនឹងត្រូវបង់ពេញតម្លៃ សំរាប់វេជ្ជបញ្ជារបស់អ្នក។ អ្នកអាចផ្ញើឲ្យយើងនូវសំណៅ នៃបង្កាន់ដៃរបស់អ្នក និងសូមឲ្យយើងសងប្រាក់អ្នកវិញ សំរាប់ចំណែកតម្លៃរបស់អ្នក។ សូមមើលជំពូកទី 5 នៃ*សៀវភៅណែនាំសមាជិក* ដើម្បីស្វែងយល់ថែមទៀត អំពីឱសថស្ថានក្រៅបណ្ដាញ។<br><br>សំរាប់ឱសថមួយចំនួន អ្នកអាចទទួលបានការផ្គត់ផ្គង់យូរ (ក៏បានហៅថា "ពន្យារការផ្គត់ផ្គង់") ដែរ នៅពេលអ្នកបំពេញវេជ្ជបញ្ជារបស់អ្នក។ ការផ្គត់ផ្គង់យូរ គឺផ្គត់ផ្គង់ដល់ទៅ 90 ថ្ងៃ។ វាគិតថ្លៃអ្នកដូចគ្នានឹងការផ្គត់ផ្គង់មួយខែដែរ។<br><br>**ការរ៉ាប់រងគ្រោះមហន្តរាយ**<br>បន្ទាប់ពីតម្លៃ ចេញពីហោប៉ៅ ប្រចាំឆ្នាំរបស់អ្នកគ្រប់ $5,000 អ្នកនឹងបង់ $0 សំរាប់ឱសថនៅក្នុងរូបមន្តនៃគំរោងរបស់អ្នក។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

| សេចក្តីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្តល់សេវាក្នុងបណ្តាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺ ឬលក្ខណៈជំងឺរបស់អ្នក** *(បន្ត)* | ឱសថឈ្មោះល្បី | ថ្លៃរួមបង់ $0 ដល់ $8.35 សំរាប់ការផ្គត់ផ្គង់ 30 ថ្ងៃ។<br><br>ថ្លៃរួមបង់ សំរាប់ឱសថមានវេជ្ជបញ្ជា អាចប្រែប្រួលអាស្រ័យលើកំរិត នៃជំនួយបន្ថែម ដែលអ្នកទទួល។ សូមទាក់ទងគំរោង សំរាប់សេចក្តីពិស្តារថែមទៀត។ | អាចនឹងមានកំរិត ទៅលើប្រភេទនៃឱសថដែលរ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលរ៉ាប់រង* (បញ្ជីឱសថ) របស់ Health Net Cal MediConnect សំរាប់ព័ត៌មានបន្ថែម។<br><br>អ្នកអាចនឹងទទួលឱសថរបស់អ្នក នៅឯបណ្តាញឱសថស្ថានលក់រាយ និងឱសថស្ថានបញ្ជាទិញផ្ញើតាមប្រៃសណីយ៍ផ្សេងទៀត។<br><br>បើសិនអ្នករស់នៅ ក្នុងមន្ទីរថែទាំយូរអង្វែង អ្នកបង់ថ្លៃដូចនឹងឱសថស្ថានលក់រាយដែរ។<br><br>នៅក្នុងករណីតិចតួចប៉ុណ្ណោះ យើងខ្ញុំនឹងរ៉ាប់រងវេជ្ជបញ្ជាដែលបានបំពេញនៅឯឱសថស្ថានក្រៅបណ្តាញ។ បើសិនអ្នកទៅឱសថស្ថានក្រៅបណ្តាញ អ្នកនឹងត្រូវបង់ពេញតម្លៃ សំរាប់វេជ្ជបញ្ជារបស់អ្នក។ អ្នកអាចផ្ញើឲ្យយើងនូវសំណៅ នៃបង្កាន់ដៃរបស់អ្នក និងសូមឲ្យយើងសងប្រាក់អ្នកវិញ សំរាប់ចំណែកតម្លៃរបស់អ្នក។ សូមមើលជំពូកទី 5 នៃ*សៀវភៅណែនាំសមាជិក* ដើម្បីស្វែងយល់ថែមទៀត អំពីឱសថស្ថានក្រៅបណ្តាញ។<br><br>សំរាប់ឱសថមួយចំនួន អ្នកអាចទទួលបានការផ្គត់ផ្គង់យូរ (ក៏បានហៅថា "ពន្យារការផ្គត់ផ្គង់") ដែរ នៅពេលអ្នកបំពេញវេជ្ជបញ្ជារបស់អ្នក។ ការផ្គត់ផ្គង់យូរគឺផ្គត់ផ្គង់ដល់ទៅ 90 ថ្ងៃ។ វាគិតថ្លៃអ្នកដូចគ្នានឹងការផ្គត់ផ្គង់មួយខែដែរ។<br><br>**ការរ៉ាប់រងគ្រោះមហន្តរាយ**<br>បន្ទាប់ពីតម្លៃ ចេញពីហោប៉ៅ ប្រចាំឆ្នាំរបស់អ្នកគ្រប់ $5,000 អ្នកនឹងបង់ $0 សំរាប់ឱសថនៅក្នុងរូបមន្តនៃគំរោងរបស់អ្នក។ |
| | ឱសថគ្មានវេជ្ជបញ្ជា | $0 | អាចនឹងមានកំរិត ទៅលើប្រភេទនៃឱសថដែលរ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលរ៉ាប់រង* (បញ្ជីឱសថ) របស់ Health Net Cal MediConnect សំរាប់ព័ត៌មានបន្ថែម។ |
| | ឱសថមានវេជ្ជបញ្ជា Medicare Part B | $0 | ឱសថ Part B រួមមានឱសថបានផ្តល់ដោយវេជ្ជបណ្ឌិតរបស់អ្នក នៅក្នុងការិយាល័យរបស់គាត់ ឬឱសថលេបខ្លះ សំរាប់រោគមហារីក និងឱសថដែលបានប្រើជាមួយ បរិក្ខារពេទ្យជាក់លាក់។ សូមអាន*សៀវភៅណែនាំសមាជិក* សំរាប់ព័ត៌មានបន្ថែមអំពីឱសថទាំងនេះ។ វិន័យការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |

# Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

| សេចក្តីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្តល់សេវាក្នុងបណ្តាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការវិធីព្យាបាលបន្ទាប់ពីមានជំងឺដាច់សរសៃឈាមខួរក្បាល ឬមានគ្រោះថ្នាក់** | វិធីព្យាបាលអាជីវកម្ម រូបកាយ ឬសំដី | $0 | វិធីព្យាបាលរូបកាយ វិធីព្យាបាលខាងអាជីវកម្ម និងវិធីព្យាបាលរោគសាស្ត្រខាងសំដី និងភាសា ដែលជារោគាព្យាបាលចាំបាច់ ត្រូវបានរ៉ាប់រង។<br>វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| **អ្នកត្រូវការថែទាំជាអាសន្ន** | សេវាបន្ទប់សង្គ្រោះបន្ទាន់ | $0 | អ្នកអាចនឹងបានរ៉ាប់រងការថែទាំសុខភាពជាអាសន្ន នៅពេលអ្នកត្រូវការវា គ្រប់ទីកន្លែងក្នុងសហរដ្ឋ ឬតំបន់ស្វ័យត្តរបស់វា។<br>ការអនុញ្ញាតជាមុន មិនតម្រូវទេ។<br>អ្នកត្រូវបានរ៉ាប់រងទូទាំងសាកលលោក សំរាប់សេវាថែទាំសុខភាពជាអាសន្ន/បន្ទាន់ ដែលបានទទួលនៅក្រៅសហរដ្ឋ។<br>មានកំរិតប្រចាំឆ្នាំ $50,000 សំរាប់ការរ៉ាប់រងភាពអាសន្ន/បន្ទាន់ ទូទាំងសាកលលោក។ |
| | សេវាឡានពេទ្យ | $0 | ការអនុញ្ញាតជាមុនមិនតម្រូវសំរាប់សេវាឡានពេទ្យ នៅក្នុងបណ្តាញ និងនៅក្រៅបណ្តាញ នៅពេលមានអាសន្នទេ។<br>សំរាប់សេវាឡានពេទ្យមិនអាសន្ន វិន័យការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | ការថែទាំបន្ទាន់ | $0 | អ្នកអាចនឹងទទួលការថែទាំជាបន្ទាន់ដែលរ៉ាប់រង នៅពេលណាអ្នកត្រូវការវា គ្រប់ទីកន្លែងនៅក្នុងសហរដ្ឋ ឬតំបន់ស្វ័យត្តរបស់ខ្លួន។ ក៏មើល "សេវាបន្ទប់សង្គ្រោះបន្ទាន់" ខាងលើ សំរាប់ការរ៉ាប់រងភាពអាសន្ន/បន្ទាន់ ទូទាំងសាកលលោក។<br>ការអនុញ្ញាតជាមុន មិនតម្រូវទេ។ |

?

**បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

## Health Net Cal MediConnect: សេចក្តីសង្ខេបអត្ថប្រយោជន៍

| សេចក្តីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្តល់សេវាក្នុងបណ្តាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការថែទាំនៅមន្ទីរពេទ្យ** | ស្នាក់នៅមន្ទីរពេទ្យ | $0 | ឥតមានកំរិតចំពោះចំនួនថ្ងៃ នៃពេលព្យាបាលចាំបាច់ដែលរ៉ាប់រងដោយគំរោងនៃការស្នាក់នៅមន្ទីរពេទ្យម្តងៗ។<br>លើកលែងតែក្នុងគ្រាអាសន្ន វេជ្ជបណ្ឌិតរបស់អ្នកត្រូវតែប្រាប់គំរោង ថាអ្នកនឹងត្រូវបានអនុញ្ញាតឲ្យចូលមន្ទីរពេទ្យ។<br>អ្នកត្រូវតែទៅជួបវេជ្ជបណ្ឌិត អ្នកឯកទេស និងមន្ទីរពេទ្យ នៅក្នុងបណ្តាញ។<br>វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត សំរាប់ស្នាក់នៅមន្ទីរពេទ្យមិនអាសន្ន។ |
| | ការថែទាំពីវេជ្ជបណ្ឌិត ឬគ្រូពេទ្យវះកាត់ | $0 | វេជ្ជបណ្ឌិត និងគ្រូពេទ្យវះកាត់ ត្រូវបានផ្តល់ឲ្យជាផ្នែកនៃការស្នាក់នៅមន្ទីរពេទ្យរបស់អ្នក។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

| សេចក្ដីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្ដល់សេវាក្នុងបណ្ដាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការជំនួយដើម្បីឲ្យបានធូរស្បើយ ឬមានសេចក្ដីត្រូវការថែទាំសុខភាពពិសេស** | សេវាស្ដារសមត្ថភាព | $0 | **សេវាស្ដារសមត្ថភាពអ្នកជំងឺឥតដេកពេទ្យ**<br>វិធីព្យាបាលរូបកាយ វិធីព្យាបាលខាងអាជីវកម្ម និងវិធីព្យាបាលធាតសាស្រ្ដខាងសំដី និងភាសា ដែលជាធាតុព្យាបាលចាំបាច់ ត្រូវបានរ៉ាប់រង។<br>វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។<br>**សេវាស្ដារសមត្ថភាពបេះដូង និងសួត**<br>វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | បរិក្ខារពេទ្យ សំរាប់ថែទាំនៅផ្ទះ | $0 | វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
| | ការថែទាំជំងឺមានជំនាញ | $0 | **មន្ទីរគិលានុបដ្ឋាកម្មមានជំនាញ (Skilled Nursing Facility, SNF)**<br>គ្មានកំរិតចំនួនថ្ងៃ ដែលរ៉ាប់រងដោយគំរោងនិមួយៗ សំរាប់ស្នាក់នៅ មន្ទីរគិលានុបដ្ឋាកម្មមានជំនាញ (skilled nursing facility, SNF) ទេ។<br>ការស្នាក់នៅមន្ទីរពេទ្យជាមុន មិនត្រូវការទេ។ វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។<br>**ការថែទាំសុខភាពតាមផ្ទះ:**<br>រួមមានការថែទាំជំងឺមានជំនាញរអាក់រអួល សេវាអ្នកជំនួយសុខភាពនៅផ្ទះ និងសេវាការស្ដារសមត្ថភាព ជាដើម។<br>វិន័យការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |

**?** **បើសិនអ្នកមានសំណួរ សូមទូរស័ព្ទទៅ** Health Net Cal MediConnect តាមលេខ 1-855-464-3571 (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ។ បន្ទាប់ពីម៉ោងធ្វើការ នៅចុងអាទិត្យ និងថ្ងៃបុណ្យ អ្នកអាចទុកសារស័ព្ទបាន។ អ្នកនឹងត្រូវបានទូរស័ព្ទមកវិញ នៅថ្ងៃធ្វើការបន្ទាប់ទៀត។ គឺឥតចេញថ្លៃឡើយ។ **សំរាប់ព័ត៌មានបន្ថែម** សូមមើល www.healthnet.com/calmediconnect។

| សេចក្តីត្រូវការ ឬបញ្ហាសុខភាព | សេវាអ្នកអាចនឹងត្រូវការ | តម្លៃរបស់អ្នក សំរាប់អ្នកផ្តល់សេវាក្នុងបណ្តាញ | ការកំរិត ការអនុគ្រោះ និងព័ត៌មានអត្ថប្រយោជន៍ (វិន័យអំពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការថែទាំភ្នែក** | ពិនិត្យភ្នែក | $0 | ការពិនិត្យចក្ខុវិញ្ញាណជាធាតាព្យាបាលចាំបាច់ សំរាប់ធាតវិនិច្ឆ័យ និងការព្យាបាលនៃជំងឺ និងលក្ខណៈជំងឺភ្នែកប្រចាំឆ្នាំ រួមទាំងការត្រួតពិនិត្យជំងឺតឹងគ្រាប់ភ្នែក សំរាប់មនុស្សបិតក្នុងហានិភ័យ។ វិន័យការបញ្ជូន អាចនឹងអនុវត្ត។<br>ការពិនិត្យភ្នែកបន្ថែមរហូតដល់ទៅ 1 ដង រៀងរាល់ឆ្នាំ។ |
| | វ៉ែនតា និងកែវភ្នែកជ័រ | $0 | វ៉ែនតាមួយគូ (កែវភ្នែកជ័រ និងដងវ៉ែនតា) ឬកែវភ្នែកជ័រ បន្ទាប់ពីការវះកាត់ជំងឺបាយភ្នែក។<br>គំរោងកំរិតការរ៉ាប់រង $250 សំរាប់គ្រឿងវ៉ែនតាបន្ថែម រួមទាំងវ៉ែនតា (កែវភ្នែកជ័រ និងដងវ៉ែនតា) ឬកែវភ្នែកជ័ រៀងរាល់ពីរឆ្នាំ។ |
| **អ្នកត្រូវការសេវា ត្រចៀក ឬសោតប្រសាទ** | ការត្រួតពិនិត្យត្រចៀក | $0 | វិន័យការបញ្ជូន និងការអនុញ្ញាតជាមុន អាចនឹងអនុវត្ត។ |
